ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ :..៩៨...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## គោលការណ៍ សមាហរណកម្ម
## មន្ត្រីរាជការស៊ីវិលទៅក្នុងក្របខ័ណ្ឌថ្មី

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ

-បានឃើញអនុក្រឹត្យលេខ ៥០ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីការស្ថិតនៅក្រៅក្របខ័ណ្ឌដើមចំពោះមន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ មន្ត្រីនគរបាលជាតិ និងកងយោធពលខេមរភូមិន្ទ

-បានឃើញអនុក្រឹត្យលេខ ៣៨ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០០០ ស្តីពីការបង្កើតគណៈកម្មការសមាហរណកម្មមន្ត្រីរាជការស៊ីវិលទៅក្នុងក្របខ័ណ្ឌថ្មី

-តាមការយល់ព្រមពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០០១

## សំរេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ ._**

អនុក្រឹត្យនេះ កំណត់គោលការណ៍សំរាប់ធ្វើសមាហរណកម្មមន្ត្រីរាជការស៊ីវិល ក្នុងក្របខ័ណ្ឌរដ្ឋបច្ចុប្បន្ន ដែលកំពុងបំពេញមុខតំណែង និងមុខងារពិតប្រាកដនៅថ្នាក់កណ្តាលនិងខេត្ត ក្រុង ផ្ទេរបញ្ចូលទៅក្នុងក្របខ័ណ្ឌថ្មី ស្របតាមលក្ខន្តិកៈដោយឡែករបស់ក្របខ័ណ្ឌនីមួយៗ ។

## ជំពូកទី ២
## គោលការណ៍សមាហរណកម្មតាមមុខតំណែង

**មាត្រា២ ._**

មន្ត្រីរាជការដែលត្រូវធ្វើសមាហរណកម្មផ្ទេរបញ្ចូលទៅក្នុងក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល និងក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ គឺមន្ត្រីទាំងឡាយ ដែលកំពុងកាន់មុខតំណែងពិតប្រាកដនៅក្នុងអង្គការលេខ នៃរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័នមាន ÷

**ក/ឋានន្តរស័ក្តិឧត្តមមន្ត្រី**

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-អគ្គលេខាធិការរងរាជរដ្ឋាភិបាល អគ្គលេខាធិការ អគ្គនាយក អគ្គាធិការ នៃក្រសួង ស្ថាប័ន

-ប្រតិភូរាជរដ្ឋាភិបាល អភិបាលខេត្ត ក្រុង

-ថ្នាក់ស្មើនឹងមុខតំណែងខាងលើ ដែលមាននៅក្នុងរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន

**ខ/ឋានន្តរស័ក្តិវរៈមន្ត្រី**

-អគ្គលេខាធិការរង អគ្គនាយករង អគ្គាធិការរង ប្រធាននាយកដ្ឋាន អធិការ នៃក្រសួង ស្ថាប័ន

-អភិបាលរងខេត្ត ក្រុង

-ថ្នាក់ស្មើនឹងមុខតំណែងខាងលើ ដែលមាននៅក្នុងរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន

**គ/ឋានន្តរស័ក្តិអនុមន្ត្រី**

-អនុប្រធាននាយកដ្ឋាន អធិការរង នៃក្រសួង ស្ថាប័ន

-ប្រធានមន្ទីរខេត្ត ក្រុង

-អភិបាលស្រុក ខ័ណ្ឌ

-ថ្នាក់ស្មើនឹងមុខតំណែងខាងលើ ដែលមាននៅក្នុងរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន ។

មាត្រា៣ .–

ការផ្ទេរមន្ត្រីបញ្ចូលទៅក្នុងថ្នាក់ នៃឋានន្តរស័ក្តិនីមួយៗរបស់ក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល និងក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ត្រូវគិតតាមចំនួនឆ្នាំបំរើការងាររដ្ឋ ដូចមានកំណត់ក្នុងតារាងឧបសម្ព័ន្ធទី ១ នៃអនុក្រឹត្យនេះ ។

មាត្រា៤ .–

មន្ត្រីរដ្ឋបាលដែលត្រូវធ្វើសមាហរណកម្មផ្ទេរបញ្ចូលទៅក្នុងក្របខ័ណ្ឌមន្ត្រីក្រមការសំរាប់អន្តរក្រសួង និងក្របខ័ណ្ឌមន្ត្រីក្រមការក្រសួងមហាផ្ទៃ គឺមន្ត្រីទាំងឡាយដែលកំពុងកាន់មុខតំណែងពិតប្រាកដនៅក្នុងអង្គការលេខនៃរចនាសម្ព័ន្ធក្រសួង ស្ថាប័នមាន ÷

**ក/ឋានន្តរស័ក្តិនាយក្រមការ**

-ប្រធានការិយាល័យក្នុងរដ្ឋបាលកណ្តាល

-អនុប្រធានមន្ទីរនៅខេត្ត ក្រុង

-អភិបាលរងស្រុក ខ័ណ្ឌ

-ថ្នាក់ស្មើនឹងមុខតំណែងខាងលើ ដែលមាននៅក្នុងរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន

**ខ/ឋានន្តរស័ក្តិក្រមការដើមខ្សែ**

-អនុប្រធានការិយាល័យក្នុងរដ្ឋបាលកណ្តាល

-ប្រធានការិយាល័យ នៃមន្ទីរនៅខេត្ត ក្រុង សាលាខេត្ត ក្រុង

-ថ្នាក់ស្មើនឹងមុខតំណែងខាងលើ ដែលមាននៅក្នុងរចនាសម្ព័នរបស់ក្រសួង ស្ថាប័ន

**គ/ឋានន្តរស័ក្តិក្រមការ**

-អនុប្រធានការិយាល័យ នៃមន្ទីរខេត្ត ក្រុង សាលាខេត្ត ក្រុង

-ថ្នាក់ស្មើនឹងមុខតំណែងខាងលើ ដែលមាននៅក្នុងរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន ។

មាត្រា៥ .–

ការផ្ទេរមន្ត្រីបញ្ចូលទៅក្នុងថ្នាក់ នៃឋានន្តរស័ក្តិនីមួយៗ របស់ក្របខ័ណ្ឌមន្ត្រីក្រមការសំរាប់អន្តរក្រសួង និងក្របខ័ណ្ឌមន្ត្រីក្រមការក្រសួងមហាផ្ទៃ ត្រូវគិតតាមចំនួនឆ្នាំបំរើការងាររដ្ឋ ដូចមានកំណត់ក្នុងតារាងឧបសម្ព័ន្ធទី ២ នៃអនុក្រឹត្យនេះ ។

មាត្រា៦ .–

មន្ត្រីគ្រប់គ្រងរដ្ឋបាល និងមន្ត្រីរដ្ឋបាលជាន់ខ្ពស់ដែលមានចែងក្នុងមាត្រា ២ បើបៀវត្សបច្ចុប្បន្នស្ថិតក្នុងកាំទី ២ ត្រូវបន្ថែមអោយមួយថ្នាក់ និងក្នុងកាំទី ៣ ត្រូវបន្ថែមអោយពីរថ្នាក់ ។

មន្ត្រីក្រមការសំរាប់អន្តរក្រសួង និងមន្ត្រីក្រមការក្រសួងមហាផ្ទៃ ដែលមានចែងក្នុងមាត្រា ៤ បើបៀវត្សបច្ចុប្បន្នស្ថិតក្នុងកាំទី ២ ត្រូវចាត់បញ្ចូលទៅក្នុងថ្នាក់លើបន្ទាប់មួយថ្នាក់ ។

ចំពោះមន្ត្រីដែលមានអតីតភាពការងារតិចជាង ៨ ឆ្នាំ កំពុងកាន់មុខតំណែង ហើយដែលត្រូវបញ្ចូលទៅក្នុងឋានន្តរស័ក្តិទី ២ ត្រូវដាក់អោយស្ថិតនៅក្នុងថ្នាក់លេខ ១០ ទោះបីបៀវត្សមន្ត្រីនោះស្ថិតក្នុងកាំទី ២ ក៏ដោយ ។

ចំពោះមន្ត្រីដែលមានអតីតភាពការងារតិចជាង ១៦ ឆ្នាំ កំពុងកាន់មុខតំណែង ហើយដែលត្រូវបញ្ចូលទៅក្នុងឋានន្តរស័ក្តិទី ១ ត្រូវដាក់អោយស្ថិតក្នុងថ្នាក់លេខ ៦ ទោះបីបៀវត្សមន្ត្រីនោះស្ថិតក្នុងកាំទី ២ ក៏ដោយ ។

**មាត្រា៧ ._**

មន្ត្រីរាជការស៊ីវិលដែលកំពុងបំរើការងារនៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រូវធ្វើសមាហរណកម្មផ្ទេរបញ្ចូលទៅក្នុងក្របខ័ណ្ឌមន្ត្រីរដ្ឋបាល ឬក្របខ័ណ្ឌមន្ត្រីការទូតក្នុងឋានន្តរស័ក្តិស្របនឹងឋានន្តរស័ក្តិនៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាល ។

## ជំពូកទី ៣

## គោលការណ៍សមាហរណកម្មតាមប្រភេទកាំបៀវត្ស

**មាត្រា៨ ._**

មន្ត្រីរាជការស៊ីវិលក្នុងក្របខ័ណ្ឌរដ្ឋ ក្រៅពីមន្ត្រីដែលត្រូវធ្វើសមាហរណកម្មទៅតាមគោលការណ៍មុខតំណែងខាងលើ ត្រូវធ្វើសមាហរណកម្មតាមប្រភេទកាំបៀវត្សបញ្ចូលក្នុងក្របខ័ណ្ឌថ្មីដូចខាងក្រោម ÷

-ខ I បញ្ចូលទៅក្នុងក្របខ័ណ្ឌប្រភេទ **ក**

-ខ II បញ្ចូលទៅក្នុងក្របខ័ណ្ឌប្រភេទ **ខ**

-ខ III , គ I និង ក II.១១ បញ្ចូលទៅក្នុងក្របខ័ណ្ឌប្រភេទ **គ**

-ខ IV , គ II , គ III និង គ IV បញ្ចូលទៅក្នុងក្របខ័ណ្ឌប្រភេទ **ឃ**

ការរៀបបញ្ចូលទៅក្នុងថ្នាក់នីមួយៗនៃក្របខ័ណ្ឌថ្មី ត្រូវបានកំណត់ដូចក្នុងតារាងឧបសម្ព័ន្ធទី៣ នៃអនុក្រឹត្យនេះ ។

**មាត្រា៩ ._**

មន្ត្រីរាជការស៊ីវិលក្នុងក្របខ័ណ្ឌរដ្ឋដែលកាំបៀវត្សបច្ចុប្បន្នស្ថិតក្នុងកាំទី ៦ នៃប្រភេទ ខ I , ខ II , ខ III , ខ IV និង គ I , គ II , គ III , គ IV ហើយមានរយៈពេលចាប់ពី ៣ ឆ្នាំឡើងទៅ ត្រូវរៀបបញ្ចូលទៅក្នុងថ្នាក់ថ្មីដោយគិតរយៈពេល ៣ ឆ្នាំ សំរាប់មួយថ្នាក់ ។

**មាត្រា១០ ._**

ក្រៅពីក្របខ័ណ្ឌមន្ត្រីដែលលក្ខន្តិកៈដោយឡែកកំណត់ ការឡើងឋានន្តរស័ក្តិផ្អែកតាមមុខតំណែងដែលទំនេរ មន្ត្រីរាជការស៊ីវិលក្នុងក្របខ័ណ្ឌរដ្ឋដែលបានរៀបបញ្ចូលទៅក្នុងថ្នាក់លេខ ១១ ឡើងទៅ អាចជ្រើសរើសយកចំនួនអតិបរមាស្មើនឹង ៣០ ភាគរយ លើចំនួនសរុបនៃក្របខ័ណ្ឌ បញ្ចូលទៅក្នុងឋានន្តរស័ក្តិទី ២ ដោយដាក់ថ្នាក់លេខ

១១ នៃឋានន្តរស័ក្តិទី ៣ បញ្ចូលទៅក្នុងថ្នាក់លេខ ១០ នៃឋានន្តរស័ក្តិទី ២ ហើយរៀបតាមលំដាប់ថ្នាក់ជាបន្តបន្ទាប់ ។

**មាត្រា១១ .-**

មន្ត្រីរាជការស៊ីវិលក្នុងក្របខ័ណ្ឌរដ្ឋដូចមានចែងក្នុងមាត្រា ៨ និងមាត្រា ១០ ដែលបានបញ្ចូលទៅក្នុងឋានន្តរស័ក្តិទី ២ ហើយស្ថិតនៅក្នុងថ្នាក់លេខ ៧ ឡើងទៅ អាចជ្រើសរើសយកចំនួនអតិបរមាស្មើនឹង ៥ ភាគរយលើចំនួនរួមនៃក្របខ័ណ្ឌនីមួយៗ បញ្ចូលទៅក្នុងឋានន្តរស័ក្តិទី ១ ដោយដាក់ថ្នាក់លេខ ៧ នៃឋានន្តរស័ក្តិទី ២ បញ្ចូលទៅក្នុងថ្នាក់លេខ ៦ នៃឋានន្តរស័ក្តិទី ១ ហើយរៀបតាមលំដាប់ថ្នាក់ជាបន្តបន្ទាប់ ។

ក្នុងករណីដែលការជ្រើសរើសយកអតិបរមា ៥ ភាគរយ បញ្ចូលទៅក្នុងឋានន្តរស័ក្តិទី ១ នេះ មិនបានតាមចំនួនសមស្រប អាចជ្រើសរើសបន្ថែមយកមន្ត្រីដែលស្ថិតក្នុងឋានន្តរស័ក្តិទី ២ ហើយមានអតីតភាពការងារចាប់ពី ១៦ ឆ្នាំឡើងទៅ ហើយមានកាំបៀវត្សបច្ចុប្បន្នខ្ពស់ជាងគេ ។

**មាត្រា១២ .-**

ការជ្រើសរើសបញ្ចូលទៅក្នុងឋានន្តរស័ក្តិទី ២ និងទី ១ ដូចមានចែងក្នុងមាត្រា ១០ និងមាត្រា ១១ ខាងលើ ត្រូវយកចិត្តទុកដាក់ចំពោះមន្ត្រីដែលមានសញ្ញាប័ត្រខ្ពស់ និងអ្នកដែលមានសមត្ថភាពបទពិសោធន៍ក្នុងការបំពេញការងារមានគុណសម្បត្តិខ្ពស់ ។

## ជំពូកទី ៤

## បទប្បញ្ញត្តិដោយឡែក

**មាត្រា១៣ .-**

មន្ត្រីដែលកំពុងកាន់មុខតំណែងដូចមានចែងក្នុងមាត្រា ៤ ហើយមានបរិញ្ញាប័ត្រ ឬមានសញ្ញាប័ត្រសមមូល ត្រូវធ្វើសមាហរណកម្មផ្ទេរបញ្ចូលទៅក្នុងក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ឬក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ឬក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ ដោយដាក់ក្នុងឋានន្តរស័ក្តិអនុមន្ត្រី ។

មន្ត្រីដែលកំពុងកាន់មុខតំណែងពិតប្រាកដដូចមានចែងក្នុងមាត្រា ២ និងមាត្រា ៤ ខាងលើ ហើយមានសញ្ញាប័ត្រជំនាញបច្ចេកទេសផ្សេងៗ អាចសុំស្ថិតនៅក្នុងក្របខ័ណ្ឌបច្ចេកទេស តាមការកំណត់របស់លក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌនីមួយៗ ។

**មាត្រា១៤ .-**

មន្ត្រីដែលកំពុងបំរើការងារក្នុងក្របខ័ណ្ឌរដ្ឋ ហើយមានកំរិតសញ្ញាប័ត្រខ្ពស់ជាងប្រភេទកាំបៀវត្ស ឬខ្ពស់ជាងមុខតំណែងរបស់ខ្លួន នៅពេលធ្វើសមាហរណកម្មត្រូវផ្ទេរបញ្ចូលទៅក្នុងក្របខ័ណ្ឌថ្មីទៅតាមកំរិតសញ្ញាប័ត្រ ។

**មាត្រា១៥ .-**

ក្រៅពីការធ្វើសមាហរណកម្មតាមមុខតំណែងដែលមានចែងក្នុងមាត្រា ២ ខាងលើ មន្ត្រីរាជការក្របខ័ណ្ឌរដ្ឋ ត្រូវធ្វើសមាហរណកម្ម ផ្ទេរបញ្ចូលទៅក្នុងក្របខ័ណ្ឌថ្មីតាមគោលការណ៍ដូចខាងក្រោម ÷

-ចំពោះមន្ត្រីដឹកនាំដែលមានប្រភេទកាំប្រៀវត្សបច្ចុប្បន្ន ក II.១ , ក II.២ , ក II.៣ ត្រូវផ្ទេរបញ្ចូលទៅក្នុងក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ឬក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ឬក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ទៅក្នុងថ្នាក់លេខ ១ នៃឋានន្តរស័ក្តិឧត្តមមន្ត្រី ។

-ចំពោះមន្ត្រីដែលមានប្រភេទកាំប្រៀវត្សបច្ចុប្បន្ន ក II.៤.១ , ក II.៤.២ , ក II.៤.៣ និង ក II.៥.១ , ក II.៥.២ ដែលតែងតាំងដោយព្រះរាជក្រឹត្យ ត្រូវផ្ទេរបញ្ចូលទៅក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី ។

-ចំពោះមន្ត្រីដែលមានប្រភេទកាំប្រៀវត្សបច្ចុប្បន្ន ក II.៦.១ , ក II.៦.២ , និង ក II.៥.១ , ក II.៥.២ ដែលតែងតាំងដោយអនុក្រឹត្យ ត្រូវផ្ទេរបញ្ចូលទៅក្នុងឋានន្តរស័ក្តិវរៈមន្ត្រី ។

-ចំពោះមន្ត្រីដែលមានប្រភេទកាំប្រៀវត្សបច្ចុប្បន្ន ក II.៧.១ និង ក II.៧.២ ត្រូវផ្ទេរបញ្ចូលទៅក្នុងឋានន្តរស័ក្តិអនុមន្ត្រី ។

ការដាក់បញ្ចូលទៅក្នុងថ្នាក់ នៃឋានន្តរស័ក្តិនីមួយៗខាងលើ ត្រូវគិតតាមការកំណត់នៃអនុក្រឹត្យលេខ ៥០ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីការស្ថិតនៅក្រៅក្របខ័ណ្ឌដើម ចំពោះមន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ មន្ត្រីនគរបាលជាតិ និងកងយោធពលខេមរភូមិន្ទ និងគិតតាមចំនួនឆ្នាំបំរើការងាររដ្ឋ ដូចមានចែងក្នុងតារាងឧបសម្ព័ន្ធទី១ នៃអនុក្រឹត្យនេះ ។

**មាត្រា១៦ .-**

ចំពោះមន្ត្រីថ្នាក់មន្ត្រីជាន់ខ្ពស់ជំនាន់ទី១ និងជំនាន់ទី២នៃសាលាភូមិន្ទរដ្ឋបាល ដែលបានទទួលជោគជ័យក្នុងការប្រឡងចេញ ត្រូវបញ្ចូលទៅក្នុងថ្នាក់លេខ ១១ ឋានន្តរស័ក្តិអនុមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ឬក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ឬក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ ឬក្របខ័ណ្ឌប្រភេទ ក របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ចំពោះមន្ត្រីថ្នាក់មធ្យមជំនាន់ទី១ និងជំនាន់ទី២នៃសាលាភូមិន្ទរដ្ឋបាល ដែលបានទទួលជោគជ័យក្នុងការប្រឡងចេញ ត្រូវបានទទួលអត្ថប្រយោជន៍ដូចខាងក្រោម ÷

-មន្ត្រីដែលមានសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិបូក២ នៅពេលប្រឡងចូលត្រូវបញ្ចូលទៅក្នុងថ្នាក់ លេខ ១៣ ឋានន្តរស័ក្តិអនុមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ឬក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ។

-មន្ត្រីដែលមានបរិញ្ញាប័ត្រ ឬសញ្ញាបត្រសមមូលនៅពេលប្រឡងចូលត្រូវបញ្ចូលទៅក្នុងថ្នាក់ លេខ ១២ ឋានន្តរស័ក្តិអនុមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ឬក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ។

**មាត្រា១៧ ._**

មន្ត្រីរាជការស៊ីវិលបច្ចុប្បន្នក្នុងក្របខ័ណ្ឌរដ្ឋដែលមានកាំបៀវត្សក្នុងប្រភេទ ខ I , ខ II , ខ III , ខ IV និង គ I , គ II , គ III , គ IV អាចធ្វើសមាហរណកម្មផ្ទេរបញ្ចូលទៅក្នុងក្របខ័ណ្ឌមន្ត្រីរដ្ឋបាលប្រភេទ **ក.ខ.គ.ឃ** បាន តាមល័ក្ខខ័ណ្ឌកំណត់ដូចមានចែងក្នុងអនុក្រឹត្យនេះ ។ មន្ត្រីទាំងនោះ រួមមានមន្ត្រីទាំងឡាយដែលកំពុងបំពេញការងារនៅ ÷

**ក/រដ្ឋបាលសំរាប់អន្តរក្រសួង**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

-ក្រសួងព្រះបរមរាជវាំង

-ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា - ព្រឹទ្ធសភា និងអធិការកិច្ច

-ក្រសួងធម្មការ និងសាសនា លើកលែងគ្រូបង្រៀនដែលត្រូវផ្ទេរបញ្ចូលទៅក្នុងក្របខ័ណ្ឌគ្រូបង្រៀន នៃក្រសួងអប់រំ យុវជន និងកីឡា

-អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋានរដ្ឋបាល អគ្គាធិការដ្ឋាន អធិការដ្ឋាន នាយកដ្ឋានរដ្ឋបាល នាយកដ្ឋានគ្រប់គ្រងបុគ្គលិក នាយកដ្ឋានហិរញ្ញវត្ថុ នាយកដ្ឋានផែនការ នៃក្រសួងស្ថាប័នដទៃក្រៅពីក្រសួងស្ថាប័នដែលរៀបរាប់ខាងលើ និងមន្ត្រីដែលធ្វើការងាររដ្ឋបាល បុគ្គលិក ហិរញ្ញវត្ថុ ផែនការនៅថ្នាក់កណ្តាល និងនៅមន្ទីរខេត្ត ក្រុង និងស្រុក ខ័ណ្ឌ ។

**ខ/រដ្ឋបាលមហាផ្ទៃ**

-ក្រសួងមហាផ្ទៃ ផ្នែករដ្ឋបាលស៊ីវិល ។

**មាត្រា១៨ ._**

ក្រសួង ស្ថាប័ននីមួយៗ ត្រូវបង្កើតគណៈកម្មការធ្វើសមាហរណកម្មមន្ត្រីរាជការស៊ីវិលមួយ ដឹកនាំដោយរដ្ឋមន្ត្រី ឬប្រធានស្ថាប័ន ដែលចាំបាច់ត្រូវមានអគ្គនាយកដ្ឋានរដ្ឋបាល ឬនាយកដ្ឋានរដ្ឋបាលបុគ្គលិក នាយកដ្ឋានបុគ្គលិក ឬការិយាល័យបុគ្គលិក ជាអ្នករៀបចំឯកសារសំរាប់ដាក់ជូនគណៈកម្មការនេះ ។

រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈមានភារកិច្ចណែនាំអំពីនីតិវិធី នៃការអនុវត្តន៍គោលការណ៍ធ្វើសមាហរណកម្មនេះ ។

## ជំពូកទី ៥

## អវសានប្បញ្ញត្តិ

**មាត្រា១៩ ._**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា២០ ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀង១ខ្លួន ។

**មាត្រា២១._**

អនុក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ ២០០១

ហ៊ុន សែន

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**និងជាប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល**

**សុខ អាន**

**កន្លែងទទួល**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា ២០

-ឯកសារ-កាលប្បវត្តិ

<u>ឧបសម្ព័ន្ធទី ១</u> នៃអនុក្រឹត្យលេខ ៨៨.អនក្រ.បក ចុះថ្ងៃទី ០៥ ខែកញ្ញា ឆ្នាំ ២០០១

# គោលការណ៍
# សមាហរណកម្មមន្ត្រីរដ្ឋបាលបច្ចុប្បន្ន
# ផ្ទេរបញ្ចូលក្នុងក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
# មន្ត្រីរដ្ឋបាលជាន់ខ្ពស់ និងមន្ត្រីការទូតជាន់ខ្ពស់

<u>**មុខតំណែងដែលត្រូវផ្ទេរបញ្ចូលទៅក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី មាន**</u> ÷

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-អគ្គលេខាធិការរងរាជរដ្ឋាភិបាល អគ្គលេខាធិការ អគ្គនាយក អគ្គាធិការ នៃក្រសួង ស្ថាប័ន

-ប្រតិភូរាជរដ្ឋាភិបាល អភិបាលខេត្ត ក្រុង

-ថ្នាក់ស្មើនឹងមុខតំណែងខាងលើ ដែលមាននៅក្នុងរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន

-មន្ត្រីរាជការស៊ីវិលដែលមានប្រភេទកាំបៀវត្សបច្ចុប្បន្ន ក.៤.១ , ក.៤.២ និង ក.៤.៣

-មន្ត្រីរាជការស៊ីវិលដែលមានប្រភេទកាំបៀវត្សបច្ចុប្បន្ន ក.៥ ដែលតែងតាំងដោយព្រះរាជក្រឹត្យ ។

| **ឋានន្តរស័ក្តិ ឧត្តមមន្ត្រី** | **<u>អតីតភាពបំរើការងាររដ្ឋ</u>** |
|---|---|
| **ថ្នាក់លេខ ១** | |
| **ថ្នាក់លេខ ២** | |
| **ថ្នាក់លេខ ៣** | ២៥ ឆ្នាំ ឡើង |
| **ថ្នាក់លេខ ៤** | ២២ - ២៥ ឆ្នាំ |
| **ថ្នាក់លេខ ៥** | ១៩ - ២២ ឆ្នាំ |
| **ថ្នាក់លេខ ៦** | ១៦ - ១៩ ឆ្នាំ |

<u>**កំណត់សំគាល់**</u> :

-ក្នុងថ្នាក់នីមួយៗ បើបៀវត្សមន្ត្រីនោះស្ថិតក្នុងកាំទី ២ ត្រូវបន្ថែមអោយ ១ ថ្នាក់ និងក្នុងកាំទី ៣ ត្រូវបន្ថែមអោយ ២ ថ្នាក់

-មន្ត្រីដែលមានអតីតភាពការងារតិចជាង ១៦ ឆ្នាំ ក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី ត្រូវដាក់អោយស្ថិតក្នុងថ្នាក់លេខ ៦ ទោះបីបៀវត្សស្ថិតនៅក្នុងកាំទី ២ ក៏ដោយ ។

**មុខតំណែងដែលត្រូវផ្ទេរបញ្ចូលនៅក្នុងឋានន្តរស័ក្តិវរៈមន្ត្រី មាន ៖**

-អគ្គលេខាធិការរង អគ្គនាយករង អគ្គាធិការរង ប្រធាននាយកដ្ឋាន អធិការ នៃក្រសួង ស្ថាប័ន

-អភិបាលរង ខេត្ត ក្រុង

-ថ្នាក់ស្មើ នឹងមុខតំណែងខាងលើ ដែលមាននៅក្នុងរចនាសម្ពន្ធ័របស់ក្រសួង ស្ថាប័ន

-មន្ត្រីរាជការស៊ីវិលដែលមានប្រភេទកាំបៀវត្សបច្ចុប្បន្ន ក II.៦.១ , ក II.៦.២ និង ក II.៥.១ , ក II.៥.២ ដែលតែងតាំងដោយអនុក្រឹត្យ ។

| ឋានន្តរស័ក្តិវរៈមន្ត្រី | អតីតភាពបំរើការងាររដ្ឋ | |
|---|---|---|
| | ប្រភេទកាំបៀវត្សបច្ចុប្បន្ន ក II.៦ | ប្រភេទកាំបៀវត្សបច្ចុប្បន្ន ក II.៥ ដែលតែងតាំងដោយអនុក្រឹត្យ |
| ថ្នាក់លេខ ១ | | |
| ថ្នាក់លេខ ២ | | |
| ថ្នាក់លេខ ៣ | | |
| ថ្នាក់លេខ ៤ | | ២៣ ឆ្នាំ ឡើង |
| ថ្នាក់លេខ ៥ | ២៣ ឆ្នាំ ឡើង | ២០ - ២៣ ឆ្នាំ |
| ថ្នាក់លេខ ៦ | ២០ - ២៣ ឆ្នាំ | ១៧ - ២០ ឆ្នាំ |
| ថ្នាក់លេខ ៧ | ១៧ - ២០ ឆ្នាំ | ១៤ - ១៧ ឆ្នាំ |
| ថ្នាក់លេខ ៨ | ១៤ - ១៧ ឆ្នាំ | ១១ - ១៤ ឆ្នាំ |
| ថ្នាក់លេខ ៩ | ១១ - ១៤ ឆ្នាំ | ៨ - ១១ ឆ្នាំ |
| ថ្នាក់លេខ ១០ | ៨ - ១១ ឆ្នាំ | |

**កំណត់សំគាល់ :**

-ក្នុងថ្នាក់នីមួយៗ បើបៀវត្សមន្ត្រីនោះស្ថិតក្នុងកាំទី ២ ត្រូវបន្ថែមអោយ ១ថ្នាក់

-មន្ត្រីដែលមានអតីតភាពការងារតិចជាង ៨ ឆ្នាំ ក្នុងឋានន្តរស័ក្តិវរៈមន្ត្រី ត្រូវដាក់អោយស្ថិតក្នុងថ្នាក់លេខ ១០ ទោះបីបៀវត្សស្ថិតក្នុងកាំទី ២ ក៏ដោយ

-មន្ត្រីដែលមានប្រភេទកាំបៀវត្ស ក II.៥.១ ត្រូវរៀបបញ្ចូលដោយគិតពីថ្នាក់លេខ ៩ នៃឋានន្តរស័ក្តិវរៈមន្ត្រី ជាចំនុចចាប់ផ្តើម ។

**មុខតំណែងដែលត្រូវផ្ទេរបញ្ចូលទៅក្នុងឋានន្តរស័ក្តិអនុមន្ត្រី មាន ÷**

-អនុប្រធាននាយកដ្ឋាន អធិការរង ប្រធានមន្ទីរខេត្តក្រុង

-អភិបាលស្រុក ខ័ណ្ឌ

-ថ្នាក់ស្មើនឹងមុខតំណែងខាងលើ ដែលមាននៅ ក្នុងរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន

-មន្ត្រីរាជការស៊ីវិលដែលមានប្រភេទកាំបៀវត្សរ៍បច្ចុប្បន្ន ក II.៧.១ , ក II.៧.២ ។

| ឋានន្តរស័ក្តិ អនុមន្ត្រី | **អតីតភាពបំរើការងាររដ្ឋ** |
|---|---|
| ថ្នាក់លេខ ១ | |
| ថ្នាក់លេខ ២ | |
| ថ្នាក់លេខ ៣ | |
| ថ្នាក់លេខ ៤ | |
| ថ្នាក់លេខ ៥ | |
| ថ្នាក់លេខ ៦ | ២៤ ឆ្នាំ ឡើង |
| ថ្នាក់លេខ ៧ | ២១ - ២៤ ឆ្នាំ |
| ថ្នាក់លេខ ៨ | ១៨ - ២១ ឆ្នាំ |
| ថ្នាក់លេខ ៩ | ១៥ - ១៨ ឆ្នាំ |
| ថ្នាក់លេខ ១០ | ១២ - ១៥ ឆ្នាំ |
| ថ្នាក់លេខ ១១ | ៩ - ១២ ឆ្នាំ |
| ថ្នាក់លេខ ១២ | ៦ - ៩ ឆ្នាំ |
| ថ្នាក់លេខ ១៣ | ៣ - ៦ ឆ្នាំ |
| ថ្នាក់លេខ ១៤ | ក្រោម ៣ ឆ្នាំ |

**កំណត់សំគាល់ :**

-ក្នុងថ្នាក់នីមួយៗ បើបៀវត្សរ៍មន្ត្រីនោះស្ថិតក្នុងកាំទី ២ ត្រូវបន្ថែមអោយ ១ថ្នាក់ ។

ឧបសម្ព័ន្ធទី ២ នៃអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី ០៥ ខែកញ្ញា ឆ្នាំ ២០០១

# គោលការណ៍
# សមាហរណកម្មមន្ត្រីរដ្ឋបាលបច្ចុប្បន្ន
# ចូលក្នុងក្របខ័ណ្ឌមន្ត្រីក្រមការ

**មុខតំណែងដែលត្រូវផ្ទេរបញ្ចូលទៅក្នុងឋានន្តរស័ក្តិនាយក្រមការ មាន ÷**

-ប្រធានការិយាល័យក្នុងរដ្ឋបាលកណ្តាល អនុប្រធានមន្ទីរនៅខេត្ត ក្រុង

-អភិបាលរងស្រុក ខ័ណ្ឌ

-ថ្នាក់ស្មើនឹងមុខតំណែងខាងលើ ដែលមាននៅក្នុងរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន ។

| ឋានន្តរស័ក្តិ នាយក្រមការ | អតីតភាពបំរើការងាររដ្ឋ |
|---|---|
| ថ្នាក់លេខ ១ | |
| ថ្នាក់លេខ ២ | |
| ថ្នាក់លេខ ៣ | ២៥ ឆ្នាំ ឡើង |
| ថ្នាក់លេខ ៤ | ២២ - ២៥ ឆ្នាំ |
| ថ្នាក់លេខ ៥ | ១៩ - ២២ ឆ្នាំ |
| ថ្នាក់លេខ ៦ | ១៦ - ១៩ ឆ្នាំ |

**កំណត់សំគាល់ :**

-ក្នុងថ្នាក់នីមួយៗ បើបៀវត្សមន្ត្រីនោះស្ថិតក្នុងកាំទី ២ ត្រូវបន្ថែមអោយ ១ ថ្នាក់

-មន្ត្រីដែលមានអតីតភាពការងារតិចជាង ១៦ ឆ្នាំ ក្នុងឋានន្តរស័ក្តិនាយក្រមការ ត្រូវដាក់អោយស្ថិតក្នុងថ្នាក់លេខ ៦ ទោះបីបៀវត្សស្ថិតក្នុងកាំទី ២ ក៏ដោយ ។

មុខតំណែងដែលត្រូវផ្ទេរបញ្ចូលនៅក្នុងឋានន្តរស័ក្តិក្រមការដើមខ្សែ មាន ÷

-អនុប្រធានការិយាល័យក្នុងរដ្ឋបាលកណ្តាល

-ប្រធានការិយាល័យ នៃមន្ទីរនៅខេត្តក្រុង សាលាខេត្តក្រុង

-ថ្នាក់ស្មើនឹងមុខតំណែងខាងលើ ដែលមាននៅក្នុងរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន ។

| ឋានន្តរស័ក្តិ ក្រមការដើមខ្សែ | **អតីតភាពបំរើការងាររដ្ឋ** |
|---|---|
| ថ្នាក់លេខ ១ | |
| ថ្នាក់លេខ ២ | |
| ថ្នាក់លេខ ៣ | |
| ថ្នាក់លេខ ៤ | |
| ថ្នាក់លេខ ៥ | ២៣ ឆ្នាំ ឡើង |
| ថ្នាក់លេខ ៦ | ២០ - ២៣ ឆ្នាំ |
| ថ្នាក់លេខ ៧ | ១៧ - ២០ ឆ្នាំ |
| ថ្នាក់លេខ ៨ | ១៤ - ១៧ ឆ្នាំ |
| ថ្នាក់លេខ ៩ | ១១ - ១៤ ឆ្នាំ |
| ថ្នាក់លេខ ១០ | ៨ - ១១ ឆ្នាំ |

កំណត់សំគាល់ :

-ក្នុងថ្នាក់នីមួយៗ បើបៀវត្សមន្ត្រីនោះស្ថិតក្នុងកាំទី ២ ត្រូវបន្ថែមអោយ ១ថ្នាក់

-មន្ត្រីដែលមានអតីតភាពការងារតិចជាង ៨ ឆ្នាំ ក្នុងឋានន្តរស័ក្តិក្រមការដើមខ្សែ ត្រូវដាក់អោយស្ថិតក្នុងថ្នាក់លេខ ១០ ទោះបីបៀវត្សស្ថិតក្នុងកាំទី ២ ក៏ដោយ ។

**មុខតំណែងដែលត្រូវផ្ទេរបញ្ចូលទៅក្នុងឋានន្តរស័ក្តិក្រមការ មាន ÷**

-អនុប្រធានការិយាល័យ នៃមន្ទីរខេត្តក្រុង សាលាខេត្តក្រុង និងថ្នាក់ស្មើនឹងមុខតំណែងខាងលើ ដែលមាននៅក្នុងរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន ។

| ឋានន្តរស័ក្តិក្រមការ | អតីតភាពបំរើការងាររដ្ឋ |
|---|---|
| ថ្នាក់លេខ ១ | |
| ថ្នាក់លេខ ២ | |
| ថ្នាក់លេខ ៣ | |
| ថ្នាក់លេខ ៤ | |
| ថ្នាក់លេខ ៥ | |
| ថ្នាក់លេខ ៦ | ២៤ ឆ្នាំ ឡើង |
| ថ្នាក់លេខ ៧ | ២១ - ២៤ ឆ្នាំ |
| ថ្នាក់លេខ ៨ | ១៨ - ២១ ឆ្នាំ |
| ថ្នាក់លេខ ៩ | ១៥ - ១៨ ឆ្នាំ |
| ថ្នាក់លេខ ១០ | ១២ - ១៥ ឆ្នាំ |
| ថ្នាក់លេខ ១១ | ៩ - ១២ ឆ្នាំ |
| ថ្នាក់លេខ ១២ | ៦ - ៩ ឆ្នាំ |
| ថ្នាក់លេខ ១៣ | ៣ - ៦ ឆ្នាំ |
| ថ្នាក់លេខ ១៤ | ក្រោម ៣ ឆ្នាំ |

**កំណត់សំគាល់ :**

-ក្នុងថ្នាក់នីមួយៗ បើបៀវត្សមន្ត្រីនោះស្ថិត ក្នុងកាំទី ២ ត្រូវបន្ថែមអោយ ១ថ្នាក់ ។

ឧបសម្ព័ន្ធទី ៣ នៃអនុក្រឹត្យលេខ ...៨៨...អនក្រ..បក..ចុះថ្ងៃទី ០៥ ខែកញ្ញា ឆ្នាំ ២០០១

## គោលការណ៍សមាហរណកម្មទៅតាមប្រភេទការបៀវត្សចូលក្នុងក្របខ័ណ្ឌប្រភេទ ក

| ឋានន្តរស័ក្តិ និងថ្នាក់ | បៀវត្សបច្ចុប្បន្ន ប្រភេទ ខ I | ផ្សេងៗ |
|---|---|---|
| ឋានន្តរស័ក្តិទី ១ | | |
| ថ្នាក់លេខ ១ | | |
| ថ្នាក់លេខ ២ | | |
| ថ្នាក់លេខ ៣ | | |
| ថ្នាក់លេខ ៤ | | |
| ថ្នាក់លេខ ៥ | | |
| ថ្នាក់លេខ ៦ | | |
| **ឋានន្តរស័ក្តិទី ២** | | |
| ថ្នាក់លេខ ១ | | |
| ថ្នាក់លេខ ២ | | |
| ថ្នាក់លេខ ៣ | | |
| ថ្នាក់លេខ ៤ | | |
| ថ្នាក់លេខ ៥ | | |
| ថ្នាក់លេខ ៦ | | |
| ថ្នាក់លេខ ៧ | | |
| ថ្នាក់លេខ ៨ | | |
| ថ្នាក់លេខ ៩ | | |
| ថ្នាក់លេខ ១០ | | |
| **ឋានន្តរស័ក្តិទី ៣** | | |
| ថ្នាក់លេខ ១ | | |
| ថ្នាក់លេខ ២ | | |
| ថ្នាក់លេខ ៣ | | |
| ថ្នាក់លេខ ៤ | | |
| ថ្នាក់លេខ ៥ | | |
| ថ្នាក់លេខ ៦ | | |
| ថ្នាក់លេខ ៧ | | |
| ថ្នាក់លេខ ៨ | | |
| ថ្នាក់លេខ ៩ | ខ I.៦ | |
| ថ្នាក់លេខ ១០ | ខ I.៥ | |
| ថ្នាក់លេខ ១១ | ខ I.៤ | |
| ថ្នាក់លេខ ១២ | ខ I.៣ | |
| ថ្នាក់លេខ ១៣ | ខ I.២ | |
| ថ្នាក់លេខ ១៤ | ខ I.១ | |

## គោលការណ៍សមាហរណកម្មទៅតាមប្រភេទការបៀវត្សចូលក្នុងក្របខ័ណ្ឌប្រភេទ ខ

| ឋានន្តរស័ក្តិ និងថ្នាក់ | បៀវត្សបច្ចុប្បន្ន ប្រភេទ ខ II | ផ្សេងៗ |
|---|---|---|
| ឋានន្តរស័ក្តិទី ១ | | |
| ថ្នាក់លេខ ១ | | |
| ថ្នាក់លេខ ២ | | |
| ថ្នាក់លេខ ៣ | | |
| ថ្នាក់លេខ ៤ | | |
| ថ្នាក់លេខ ៥ | | |
| ថ្នាក់លេខ ៦ | | |

ឋានន្តរស័ក្តិទី ២

| | | |
|---|---|---|
| ថ្នាក់លេខ ១ | | |
| ថ្នាក់លេខ ២ | | |
| ថ្នាក់លេខ ៣ | | |
| ថ្នាក់លេខ ៤ | | |
| ថ្នាក់លេខ ៥ | | |
| ថ្នាក់លេខ ៦ | | |
| ថ្នាក់លេខ ៧ | | |
| ថ្នាក់លេខ ៨ | | |
| ថ្នាក់លេខ ៩ | | |
| ថ្នាក់លេខ ១០ | | |

ឋានន្តរស័ក្តិទី ៣

| | | |
|---|---|---|
| ថ្នាក់លេខ ១ | | |
| ថ្នាក់លេខ ២ | | |
| ថ្នាក់លេខ ៣ | | |
| ថ្នាក់លេខ ៤ | | |
| ថ្នាក់លេខ ៥ | | |
| ថ្នាក់លេខ ៦ | | |
| ថ្នាក់លេខ ៧ | | |
| ថ្នាក់លេខ ៨ | | |
| ថ្នាក់លេខ ៩ | ខ II.៦ | |
| ថ្នាក់លេខ ១០ | ខ II.៥ | |
| ថ្នាក់លេខ ១១ | ខ II.៤ | |
| ថ្នាក់លេខ ១២ | ខ II.៣ | |
| ថ្នាក់លេខ ១៣ | ខ II.២ | |
| ថ្នាក់លេខ ១៤ | ខ II.១ | |

| ឋានន្តរស័ក្តិ និងថ្នាក់ | បៀវត្សរ៍បច្ចុប្បន្ន | | | ផ្សេងៗ |
|---|---|---|---|---|
| | ប្រភេទ ខ III | ប្រភេទ គ I | ប្រភេទ ក II.១១ | |
| ឋានន្តរស័ក្តិទី ១ | | | | |
| ថ្នាក់លេខ ១ | | | | |
| ថ្នាក់លេខ ២ | | | | |
| ថ្នាក់លេខ ៣ | | | | |
| ថ្នាក់លេខ ៤ | | | | |
| ថ្នាក់លេខ ៥ | | | ក II.១១.២ | |
| ថ្នាក់លេខ ៦ | | | ក II.១១.១ | |
| ឋានន្តរស័ក្តិទី ២ | | | | |
| ថ្នាក់លេខ ១ | | | | |
| ថ្នាក់លេខ ២ | | | | |
| ថ្នាក់លេខ ៣ | | | | |
| ថ្នាក់លេខ ៤ | | | | |
| ថ្នាក់លេខ ៥ | | | | |
| ថ្នាក់លេខ ៦ | | | | |
| ថ្នាក់លេខ ៧ | | | | |
| ថ្នាក់លេខ ៨ | | | | |
| ថ្នាក់លេខ ៩ | | | | |
| ថ្នាក់លេខ ១០ | | | | |
| ឋានន្តរស័ក្តិទី ៣ | | | | |
| ថ្នាក់លេខ ១ | | | | |
| ថ្នាក់លេខ ២ | | | | |
| ថ្នាក់លេខ ៣ | | | | |
| ថ្នាក់លេខ ៤ | | | | |
| ថ្នាក់លេខ ៥ | | | | |
| ថ្នាក់លេខ ៦ | | | | |
| ថ្នាក់លេខ ៧ | | គ I.៦ | | |
| ថ្នាក់លេខ ៨ | | គ I.៥ | | |
| ថ្នាក់លេខ ៩ | ខ III.៦ | គ I.៤ | | |
| ថ្នាក់លេខ ១០ | ខ III.៥ | គ I.៣ | | |
| ថ្នាក់លេខ ១១ | ខ III.៤ | គ I.២ | | |
| ថ្នាក់លេខ ១២ | ខ III.៣ | គ I.១ | | |
| ថ្នាក់លេខ ១៣ | ខ III.២ | | | |
| ថ្នាក់លេខ ១៤ | ខ III.១ | | | |

## គោលការណ៍សមាហរណកម្មទៅតាមប្រភេទការបៀវត្សចូលក្នុងប្រភេទ ឃ

| ឋានន្តរស័ក្តិ និងថ្នាក់ | បៀវត្សបច្ចុប្បន្ន | | | | ផ្សេងៗ |
|---|---|---|---|---|---|
| | ប្រភេទ គ IV | ប្រភេទ គ III | ប្រភេទ គ II | ប្រភេទ ខ IV | |
| **ឋានន្តរស័ក្តិទី ១** | | | | | |
| ថ្នាក់លេខ ១ | | | | | |
| ថ្នាក់លេខ ២ | | | | | |
| ថ្នាក់លេខ ៣ | | | | | |
| ថ្នាក់លេខ ៤ | | | | | |
| ថ្នាក់លេខ ៥ | | | | | |
| ថ្នាក់លេខ ៦ | | | | | |
| **ឋានន្តរស័ក្តិទី ២** | | | | | |
| ថ្នាក់លេខ ១ | | | | | |
| ថ្នាក់លេខ ២ | | | | | |
| ថ្នាក់លេខ ៣ | | | | | |
| ថ្នាក់លេខ ៤ | | | | | |
| ថ្នាក់លេខ ៥ | | | | | |
| ថ្នាក់លេខ ៦ | | | | | |
| ថ្នាក់លេខ ៧ | | | | | |
| ថ្នាក់លេខ ៨ | | | | | |
| ថ្នាក់លេខ ៩ | | | | | |
| ថ្នាក់លេខ ១០ | | | | | |
| **ឋានន្តរស័ក្តិទី ៣** | | | | | |
| ថ្នាក់លេខ ១ | | | | | |
| ថ្នាក់លេខ ២ | | | | | |
| ថ្នាក់លេខ ៣ | | | | | |
| ថ្នាក់លេខ ៤ | | | | | |
| ថ្នាក់លេខ ៥ | | | | | |
| ថ្នាក់លេខ ៦ | | | គ II.៦ | | |
| ថ្នាក់លេខ ៧ | | គ III.៦ | គ II.៥ | | |
| ថ្នាក់លេខ ៨ | | គ III.៥ | គ II.៤ | ខ IV.៦ | |
| ថ្នាក់លេខ ៩ | គ IV.៦ | គ III.៤ | គ II.៣ | ខ IV.៥ | |
| ថ្នាក់លេខ ១០ | គ IV.៥ | គ III.៣ | គ II.២ | ខ IV.៤ | |
| ថ្នាក់លេខ ១១ | គ IV.៤ | គ III.២ | គ II.១ | ខ IV.៣ | |
| ថ្នាក់លេខ ១២ | គ IV.៣ | គ III.១ | | ខ IV.២ | |
| ថ្នាក់លេខ ១៣ | គ IV.២ | | | ខ IV.១ | |
| ថ្នាក់លេខ ១៤ | គ IV.១ | | | | |